2-Mrs. Tokuyo Sato , CEAF Advisor
3-Mrs. Kong Vorn , CEAF Representative in Cambodia
4-Mrs. Keo Sopheap , CEAF Member

**មាត្រា ២ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

**អ៊ុង ហួត ហ៊ុន សែន**

★ ★ ★

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៨

### សេចក្តីសំរេចលេខ ៣៨ សសរ

### ស្តីពីការចាត់តាំងតំណាងរាជរដ្ឋាភិបាល ជាសមាជិកក្រុមប្រឹក្សាស្ថាបនិក នៃមជ្ឈមណ្ឌលអន្តរជាតិផ្នែកដោះមីនដោយមនុស្សធម៌នៅហ្សឺណែវ

***

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការសំរួលសមាសភាពថ្មី របស់រាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណើរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

### សំរេច

**ប្រការ ១ :** ចាត់តាំងឯកឧត្តម អៀង មូលី ប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិសកម្មភាពកំចាត់មីនកម្ពុជា ជាតំណាងរបស់រាជរដ្ឋាភិបាល ក្នុងតួនាទីជាសមាជិកក្រុមប្រឹក្សាស្ថាបនិកនៃមជ្ឈមណ្ឌលអន្តរជាតិផ្នែកដោះមីន ដោយមនុស្សធម៌ នៅហ្សឺណែវ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងឯកឧត្តម អៀង មូលី ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ និង ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

★ ★ ★

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៨

**សេចក្តីសំរេចលេខ ៣៥ សសរ**

**ស្តីពីការបង្កើតក្រុមអធិការកិច្ចលើក្រុមហ៊ុន**

**អាកាសចរភូមិន្ទកម្ពុជា**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៩៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញសេចក្តីសំរេចលេខ ០៧ សសរ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការព្យួរការអនុវត្តន៍តួនាទីភារកិច្ចរបស់គណៈកម្មការត្រួតពិនិត្យចំណូលថវិការដ្ឋ

-ផ្អែកតាមតំរូវការការងារចាំបាច់

**សំរេច**

ប្រការ ១ : បង្កើតក្រុមអធិការកិច្ច លើក្រុមហ៊ុនអាកាសចរភូមិន្ទកម្ពុជា ( **RAC** ) ដែលមានសមាសភាពដូចតទៅ ៖

១-ឯកឧត្តម ចាន់ គិន ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ ប្រធាន